# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ២០១៣

## ជប៉ុនផ្តល់ ៧៧,២៨៣ ដុល្លារអាមេរិក សម្រាប់គម្រោងសាងសង់អគារសិក្សា



ក្រោមគ្រោងការណ៍នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរបស់ជប៉ុន ជំនួយឧបត្ថម្ភឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ (ជំនួយគូសាណូណិ) រដ្ឋាភិបាលជប៉ុនបានផ្តល់ទឹកប្រាក់សរុបចំនួន ៧៧,២៨៣ ដុល្លាអាមេរិកដល់អង្គការអប់រំវិជ្ជាជីវដើម្បីកាត់បន្ថយភាពក្រីក្រ និង អភិវឌ្ឍន៍សង្គមសម្រាប់គម្រោងសាងសង់អគារសិក្សាក្នុងសាលាបឋមសិក្សារលោប ខេត្តពោធិ៍សាត់។ កិច្ចសន្យាផ្តល់ជំនួយត្រូវបានចុះហត្ថលេខាថ្ងៃនេះដោយលោក យ៉ូស៊ី ហ៊ីរ៉ូហ៊ីហ្គជិ ឧបទូតស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និង លោក ថោង សារុណ នាយកប្រតិបត្តិអង្គការអប់រំវិជ្ជាជីវដើម្បីកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍សង្គមនៅស្ថានទូតជប៉ុន។



ដើម្បីកែលម្អបរិស្ថានអប់រំ អង្គការ អប់រំវិជ្ជាជីវដើម្បីកាត់បន្ថយភាពក្រីក្រ និង អភិវឌ្ឍន៍សង្គម នឹងអនុវត្តគម្រោងសាងសង់អគារសិក្សាថ្មមួយខ្នងមាន៥បន្ទប់ រួមទាំងការបំពាក់គ្រឿងសង្ហារឹមនៅសាលាបឋមសិក្សារលោប ក្នុង ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់។ ជាផ្នែកមួយក្នុងគម្រោងនេះដែរ បង្គន់អនាម័យដែលមាន៤បន្ទប់ក៏នឹងត្រូវបានសាងសង់ផងដែរ។ យើងរំពឹងថា សិស្សានុសិស្ស ជាង៥០០ នាក់នឹងរីករាយជាមួយបរិស្ថានអប់រំកាន់តែប្រសើរ។

កម្មវិធីជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ (*ជំនួយគូសាណូណិ*) របស់រដ្ឋាភិបាលជប៉ុនបានចាប់ផ្តើមតាំងពីឆ្នាំ១៩៩១ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍន៍ និង ស្តាបនាប្រទេសឡើងវិញនៅតាមកំរិតមូលដ្ឋាន។ គម្រោងជំនួយនេះមានទិសដៅការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជា ភាពក្រីក្រ និង ភាពអកុសលដែលអាចគំរាមកំហែងដោយផ្ទាល់ដល់ជីវភាពរស់នៅ ការ ចិញ្ចឹមជិវិត និង សេចក្តីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជា ជួយជំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១ រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង៤៨.៣លានដុល្លាអាមេរិកដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាលដើម្បីអនុវត្តគម្រោងចំនួន ៤៨១ គម្រោង នៅទូទាំង ប្រទេស។



---

ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

ទូរសព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០

អ៊ីមែល: eco.jpn@.pp.mofa.go.jp

គេហទំព័រ: http://www.kh.emb-japan.go.jp